# មេរៀនទី១១៣៖ ព្រះយេស៊ូវបានប្រទានព្រះពរដ៏ពិត

## ម៉ាថាយ ៥៖១-១២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/-qJZvB4cm7M

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/rvweW3lLVd4

**គោលបំណង៖** ព្រះសព្វព្រះទ័យអស់អ្នកដែលបន្ទាបខ្លួន។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៥៖៣** *"មានពរហើយ អស់អ្នកដែលមានសេចក្ដីកំសត់ខាងឯវិញ្ញាណ ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំដឹងថា https://youtu.be/ywt-KvGIQcE

២. គឺជាការល្អ https://youtu.be/Z91SULEHfho

៣. ចូរបន្ទាបខ្លួននៅចំពោះព្រះអង្គ https://youtu.be/7WO74xMesGU

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «រាប់ផ្លែឈើ»




សម្ភារៈដែលត្រូវការ៖ ក្រដាស និងខ្មៅដៃ

១. ចែកកុមារជា ៣ ឬ ៤ក្រុម ហើយឲ្យក្រដាសនិងខ្មៅដៃទៅក្រុមនីមួយៗ។

២. ឲ្យកុមារគ្រប់ក្រុមទាំងអស់សរសេរឈ្មោះផ្លែឈើទាំងអស់ដែលពួកគេស្គាល់ ក្នុងរយៈពេល២នាទី។

៣. បន្ទាប់មកគ្រូប្រមូលក្រដាសទាំងអស់ពីគ្រប់ក្រុម ហើយធ្វើការរាប់ក្រុមណាដែលអាចសរសេរឈ្មោះបានច្រើនជាគេក្រុមនោះជាអ្នកឈ្នះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងមិនអាចចងចាំផ្លែឈើទាំងអស់ ដែលព្រះបានបង្កើតនោះទេ។ ក៏ដូចគ្នានេះដែលយើងមិនអាចរាប់ព្រះពរ ដែលព្រះបានប្រទានឲ្យដល់យើងអស់នោះទេ។

### ៤. ការណែនាំមេរៀន

តើអ្នកនឹងធ្វើដូចម្ដេចនៅពេលដែលអ្នកជួបគ្រូរបស់ប្អូននោះ? នៅពេលអ្នកទៅលេងផ្ទះយាយតាតើអ្នកធ្វើដូចម្ដេច? ចុះនៅពេលមានចាស់ទុំមកលេងផ្ទះ តើអ្នកនឹងធ្វើដូចម្ដេច?តើអ្នកមានអាកប្បកិរិយាបែបណានៅពេលដែលអ្នកនិយាយជាមួយមិត្តភក្តិរបស់អ្នក? តើអ្នកធ្វើខ្លួនជាមេ គេឬក៏អ្នកចិត្តល្អនិងបន្ទាបខ្លួនជាមួយគេ? ចុះនៅពេលដែលអ្នកនិយាយជាមួយតាយាយរបស់អ្នក? តើអ្នកបន្ទាបខ្លួនដាក់ពួកគាត់ឬក៏អ្នកឈ្លើយជាមួយពួកគាត់? ថ្ងៃនេះយើងនឹងរៀនពីអាកប្បកិរិយាដ៏សំខាន់ ដែលយើងគួរធ្វើ ដើម្បីឲ្យយើងអាចទទួលរង្វាន់នៅឯនគរឋានសួគ៌។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

(ព្រីនក្រដាសហត្ថកម្ម និងប្រើវាដើម្បីប្រាប់ពីរឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ)

រឿងនៅក្នុងព្រះគម្ពីររបស់យើងនៅថ្ងៃនេះ គឺដកស្រង់ចេញពីផ្នែកមួយនៅក្នុងព្រះគម្ពីរដែលនិយាយអំពីព្រះពរដ៏ពិតប្រាកដ។ នៅក្នុងខគម្ពីរទាំងនោះ ព្រះយេស៊ូវនិយាយអំពីអាកប្បកិរិយា ដែលយើងគួរធ្វើតាមលំដាប់លំដោយ ដើម្បីឲ្យព្រះសព្វព្រះទ័យ។ ព្រះក៏បានបង្រៀនពួកយើង ប្រសិនបើយើងមានអាកប្បកិរិយាល្អទាំងអស់នោះ នោះយើងនឹងទទួលបានរង្វាន់នៅឯនគរឋានសួគ៌។ ដូច្នេះ វាពិតជាមានសារៈសំខាន់ណាស់ដែលយើងត្រូវតែយល់ពីអាកប្បកិរិយាទាំងប្រាំបីនោះ។

១. ឲ្យកុមារកាត់រង្វង់មូលចេញមកហើយនិយាយថា “ មានពរហើយ……”
២. កាត់ពាក្យ “ដែលមានសេចក្តីកំសត់ខាងឯវិញ្ញាណ” និងពន្យល់ពួកគេថាវាមានន័យថា ការដែលបន្ទាបខ្លួន ដោយគិតពីអ្នកដទៃមុន និងមិនអួតខ្លួន។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។
៣. កាត់ពាក្យ “ដែលយំសោក” និងពន្យល់ពួកគេថាវាមានន័យថា នៅពេលដែលអ្នកកើតទុក្ខ ព្រះនឹងការពារអ្នក។ ហើយវាគឺជាការពិតដ៏ពិសេសនៅពេលដែលយើងកើតទុក្ខ ចំពោះអ្នកដែលមិនជឿលើព្រះនោះ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។
៤. កាត់ពាក្យ “ដែលស្លូតត្រង់” និងពន្យល់ពួកគេថាវាមានន័យថា ការដែលចេះអត់ធ្មត់ ដោយមិនមានការខឹងចំពោះអ្នកដទៃ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។
៥. កាត់ពាក្យ “ដែលស្រេកឃ្លាននូវសេចក្តីសុចរិត” និងពន្យល់ពួកគេថាវាមានន័យថា ធ្វើតែអ្វីដែលត្រឹម ត្រូវជាមួយព្រះ និងស្តាប់ព្រះទ័យទ្រង់។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។
៦. កាត់ពាក្យ “ ដែលមានចិត្តមេត្តាករុណា” និងពន្យល់ពួកគេថាវាមានន័យថា បង្ហាញពីសន្តានចិត្តល្អសម្រាប់អ្នកដទៃ ជំនួសឲ្យការវាយតម្លៃលើពួកគេ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។
៧. កាត់ពាក្យ “ដែលមានចិត្តបរិសុទ្ធ” និងពន្យល់ពួកគេថា វាមានន័យថា គឺមានតែដួងចិត្តដែលធ្វើឲ្យព្រះ សប្បាយព្រះទ័យ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។
៨. កាត់ពាក្យ “ដែលផ្សះផ្សាគេ” និងពន្យល់ពួកគេថាវាមានន័យថា ធ្វើខ្លួនឲ្យល្អ ដោយមានសន្តិភាពជាមួយនឹងមនុស្សគ្រប់គ្នា ដោយមិនមានការឈ្លោះប្រកែកគ្នា ឬក៏ភាពអាត្មានិយមនោះឡើយ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។
៩. កាត់ពាក្យ “ដែលត្រូវគេបៀតបៀន” និងពន្យល់ពួកគេថា វាមានន័យថាយើងអាចទទួលរងនូវការធ្វើបាបពីអ្នកដ៏ទៃ ដោយព្រោះយើងស្រលាញ់ព្រះ បម្រើព្រះ ប៉ុន្តែយើងនៅតែបន្តសេចក្តីស្រលាញ់របស់យើងចំពោះព្រះអង្គ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

ឥឡូវនេះអ្នកមានផ្កាមួយទង!

នៅពេលដែលយើងបន្ទាបខ្លួននៅចំពោះព្រះនោះយើងនឹងទទួលបាននូវពរដ៏ពិតប្រាដក។ ផ្នែកមួយនៃភាពជាមនុស្ស គឺយើងត្រូវស្វែងយល់ថាតើអ្វីដែលព្រះទ្រង់សព្វព្រះទ័យ និងយល់ពីទំនាក់ទំនងរបស់យើងជាមួយទ្រង់។ ព្រះគម្ពីរបានប្រាប់យើងថាព្រះបានបង្កើតផែនដីនេះ ហើយទ្រង់គឺជាព្រះ ទ្រង់បានសោយរាជ្យជាស្តេចនៃឋានសួគ៌។ ព្រះយេស៊ូវគឺជាព្រះដ៏បរិសុទ្ធ និងជាព្រះសុចរិត។

ប្រសិនបើយើងឃើញគំរូរបស់នរណាម្នាក់ នោះវាគឺពិតជាងាយស្រួលខ្លាំងមែនទែន ដែលធ្វើឲ្យ យើងមានមោទនភាពចំពោះខ្លួនឯង និងមិនបន្ទាបខ្លួននោះ។ ប៉ុន្តែប្រសិនបើយើងមើលឃើញពីគំរូរបស់ព្រះយេស៊ូវនោះ យើងនឹងងាយស្រួលក្នុងការបន្ទាបខ្លួន ពីព្រោះព្រះយេស៊ូវគឺសប្បុរស និងបន្ទាបខ្លួន បើទោះបីជាទ្រង់ជាព្រះដ៏មានព្រះចេស្តាក៏ដោយ។ នៅពេលដែលយើងមានសេចក្តីសប្បុរស សេចក្តីស្រលាញ់ និងពេញដោយសេចក្តីមេត្តាករុណា នោះយើងនឹងមិនសូវជាខ្វល់ខ្វាយពីភាពសំខាន់ សម្រាប់ខ្លួននោះ

ទេ។ គឺយើងខ្វល់ខ្វាយសម្រាប់អ្នកដទៃ។ នេះគឺជាឧទាហរណ៍នៃការសុភាព ឬការបន្ទាប ខ្លួន។ ប្រសិនបើដួងចិត្តរបស់យើងចេះបន្ទាបចុះ នោះអាកប្បកិរិយារបស់យើងក៏ធ្វើបានត្រឹមត្រូវ ហើយយើងអាចស្រលាញ់អ្នកជុំវិញយើងបាន។

**៦. សំនួរពិភាក្សា**

១. តើពរដ៏ពិតទាំងអស់មានប៉ុន្មាន? *(ប្រាំបី)*

២. តើនរណាជាគំរូដ៏ល្អដែលជួយយើង ដើម្បីឲ្យយើងអាចបន្ទាបខ្លួនបាន?
*(ព្រះយេស៊ូវគឺជាម្នាក់ដែលសុចរិតនិងបន្ទាបខ្លួន ទោះបីជាទ្រង់ជាព្រះដ៏មានព្រះចេស្តាក៏ដោយ)*

៣. សូមមើលទៅផ្កានៃពរពិតរបស់អ្នក។ តើអ្នកគិតថាផ្នែកណាមួយដែលអ្នកគិតថាពិបាកថែរក្សាជាងគេ? *(ទុកឲ្យកុមារជាអ្នកឆ្លើយ)*

**៧. ល្បែងកំសាន្ត** **«ដណ្តើមក្រដាសពណ៌»**

សម្ភារៈដែលត្រូវការ៖ ៣ ឬ ៤ សន្លឹកនៃក្រដាសពណ៌ខុសៗគ្នា

១. គ្រូត្រូវកាត់ក្រដាសពណ៌នោះ ជារាងតូចៗហើយបិតវានៅកណ្តាលថ្នាក់រៀន

២. នៅពេលដែលគ្រូនិយាយថា "១ ២ ៣ ទៅ" ហើយសិស្សត្រូវរត់ទៅយកក្រដាសមួយពណ៌

៣. បន្ទាប់ពីយកក្រដាសបានហើយ កុមារដែលចាប់បានក្រដាសពណ៌ដូចគ្នាត្រូវរត់រកគ្នា




៤. ក្រុមណាមានគ្នាច្រើនជាគេក្រុមនោះជាអ្នកឈ្នះ

៥. កុមារដែលឈ្នះត្រូវដើរទៅរកកុមារដែលចាញ់ហើយនិយាយថា "ឯងធ្វើបានល្អហើយ"

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា មនុស្សខ្លះប្រឈមមុខនឹងការបៀតបៀនកាន់តែច្រើន ហើយអ្នកខ្លះប្រឈមមុខនឹងការបៀតបៀនតិចជាងមុន ប៉ុន្តែយើងត្រូវតែបន្តនូវការចេះបន្ទាបខ្លួននេះ ពីព្រោះវាធ្វើឲ្យព្រះសព្វព្រះទ័យ។

**៨. ខគម្ពីរចងចាំ**

**ម៉ាថាយ ៥៖៣** *"មានពរហើយ អស់អ្នកដែលមានសេចក្តីកំសត់ខាងឯវិញ្ញាណ ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ។"*

**៩. ហត្ថកម្ម** **«ពរដ៏ពិត»**

សម្ភារៈដែលត្រូវការ៖ ព្រីនក្រដាសហត្ថកម្ម និងកូល័រ

សូមធ្វើតាមការណែនាំរឿងនៅក្នុងព្រះគម្ពីរដើម្បីធ្វើផ្កានៃព្រះពរដ៏ពិត។

សូមឲ្យកុមារតុបតែងនិងផាត់ពណ៌ផ្កានៃព្រះពរដ៏ពិតនោះ។



**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ព្រះយេស៊ូវបានធ្វើការអធិប្បាយនៅពីមុខហ្វូងមនុស្សជាច្រើន ប៉ុន្តែទ្រង់បានប្រាប់ទិសដៅនៃព្រះពរដល់អ្នកដើរតាមទ្រង់។ ការដើរតាមព្រះយេស៊ូវមានតម្លៃ ប៉ុន្តែក៏មានរង្វាន់ដ៏អស្ចារ្យដែរ។ សូមអានព្រះគម្ពីរ **ម៉ាថាយ៥៖១-១២** សារឡើងវិញ។ តើព្រះពរមួយណាដែលបានកើតឡើងពិតនៅក្នុងជីវិតរបស់អ្នក?តើពរពិតមួយណាដែលអ្នកចង់ឲ្យព្រះយេស៊ូវជួយធ្វើឲ្យកើតមានយ៉ាងពិតប្រាដកនៅក្នុងជីវិតអ្នក?ព្រះយេស៊ូវចង់ឲ្យសារទាំងនេះជាអ្នករៀបរាប់ពីអ្នក។ ទ្រង់នឹងផ្តល់ឲ្យអ្នកនូវជំនួយគ្រប់យ៉ាងដែលអ្នកចង់បាន។

# ពរដ៏ពិត

ដែលមានសេចក្តីកំសត់ ខាងវិញ្ញាណ

ដែលយំសោក

ដែលស្លូតត្រង់

ដែលស្រេកឃ្លាននូវ សេចក្តីសុចរិត

ដែលមានចិត្តមេត្តាករុណា

ដែលមានចិត្តបរិសុទ្ធ

ដែលផ្សះផ្សាគេ

មានពរហើយ…

ដែលត្រូវគេបៀតបៀន

